ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល
(ខេមបូឌា) ភីអិលស៊ី

*ថ្ងៃ អង្គារ ៤រោច ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី ៣៦ អាណត្តិទី២ របស់ ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ចាប់ពីម៉ោង ៩:០០ ព្រឹក នៅទីស្នាក់ការក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ("**ក្រុមហ៊ុន**") ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា តាមរយៈការប្រជុំពីចម្ងាយ (ZOOM Meeting) លោក **Yang Shaw Shin** ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី ៣៦ របស់ក្រុមហ៊ុន។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៣៦ អាណត្តិទី២ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុលលើខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលទទួលបានលទ្ធផល និងអនុម័ត ដូចខាងក្រោម៖

១. លទ្ធផលអាជីវកម្មសម្រាប់ត្រីមាសទី ២ ឆ្នាំ២០២២ និងផែនការសម្រាប់ត្រីមាសបន្ទាប់ ឆ្នាំ២០២២
២. ការបោះឆ្នោត និងការជ្រើសតាំងប្រធានក្រុមប្រឹក្សាភិបាលថ្មីរបស់ក្រុមហ៊ុន
៣. វឌ្ឍនភាពនៃការផ្ទេរកម្មសិទ្ធនៃអគារ Gateway ជាមួយក្រសួង និងភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ
៤. ផែនការនៃការទិញយកភាគហ៊ុនត្រលប់មកវិញ ដោយក្រុមហ៊ុនផ្ទាល់
៥. កម្ចីរយៈពេលខ្លីពីធនាគារមេហ្គា អ៊ិនធើណេសិនណល ខមមើសល ប៊ែង ខូអិលធីឌី
៦. បញ្ហាផ្សេងៗ

អង្គប្រជុំបានបញ្ចប់ទៅនៅវេលាម៉ោង ១១:៣០ ព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

**ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី**

ទីស្នាក់ការ: ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:(៨៥៥)២៣ ៨៩០ ៣២៥ /ទូរសារ : (៨៥៥)២៣ ៨៩០ ៣២៦/ គេហទំព័រ : www.Grandtwins.com.kh/ អ៊ីម៉ែល : vuthy.phuong@qmico.com